និយ័តករគណនេយ្យនិងសវនកម្ម
ព្រឹត្តិបត្រព័ត៌មានប្រចាំខែតុលា ឆ្នាំ២០២៤
លេខ:០១០

សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែតុលា របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

## កិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈកម្មសិទ្ធិ និងភាគហ៊ុនរបស់រដ្ឋ




១.កាលពីថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែតុលា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈកម្មសិទ្ធិនិងភាគហ៊ុនរបស់រដ្ឋ តាមរយៈប្រព័ន្ធអនឡាញ ដែលដឹកនាំដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។

## កិច្ចប្រជុំស្តីពីសេចក្តីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




## ព័ត៌មានថ្មីៗ

កិច្ចប្រជុំថ្នាក់ដឹកនាំ សូមអាននៅទំព័រ.....................១
កិច្ចប្រជុំស្តីពី សូមអាននៅទំព័រ.............................២
កិច្ចប្រជុំលើសេចក្តីសម្រេច សូមអាននៅទំព័រ............២
វេទិកាគណនេយ្យសាធារណៈ សូមអាននៅទំព័រ.......៣
កិច្ចប្រជុំវឌ្ឍនភាព សូមអាននៅទំព័រ .....................៣
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................៤
កិច្ចប្រជុំ សូមអាននៅទំព័រ....................................៤
កិច្ចប្រជុំពិគ្រោះយោបល់ សូមអាននៅទំព័រ..............៥
កិច្ចប្រជុំ សូមអាននៅទំព័រ....................................៥
បិទវគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ...................៦
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ.....................៦
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ........................៧
កិច្ចប្រជុំដើម្បីពិនិត្យ សូមអាននៅទំព័.....................៧
កិច្ចប្រជុំដើម្បីពិនិត្យ សូមអាននៅទំព័.....................៨
វេទិកាជាតិគណនេយ្យ សូមអាននៅទំព័រ.................៨
កិច្ចពិភាក្សា សូមអាននៅទំព័រ.................................៩
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៩
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.......................១០
កម្មវិធីគម្រប់ខួប ២០ឆ្នាំ សូមអាននៅទំព័រ............១១
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.......................១១
កិច្ចប្រជុំលើកទី១ សូមអាននៅទំព័រ.....................១២
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.......................១២
ពិធីប្រកាសផ្សព្វផ្សាយ សូមអាននៅទំព័រ..............១៣
ពិធីចុះអនុស្សរណៈ សូមអាននៅទំព័រ..................១៣
គោរពវិញ្ញាណក្ខន្ធ សូមអាននៅទំព័រ.....................១៤
កិច្ចប្រជុំស្តីពី សូមអាននៅទំព័រ...........................១៤
វេទិកាបរធនបាលកិច្ច សូមអាននៅទំព័រ................១៥
កម្មវិធីប្រគល់វិញ្ញាបនបត្រ សូមអាននៅទំព័រ..........១៥
កិច្ចប្រជុំ សូមអាននៅទំព័រ...................................១៦

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២.កាលពីថ្ងៃពុធ ១៤កើត ខែកទ្រេបទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.២០២៤ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិ**យ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនាយកដ្ឋានកិច្ចការទូទៅ និង**លោក ជីវ ហ៊ា** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា បានចូលរួមកិច្ចប្រជុំស្ដីពីសេចក្ដីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធអនឡាញ ដែលដឹកនាំដោយ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។**

## កិច្ចប្រជុំលើសេចក្ដីសម្រេចស្ដីពី " ការបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពរ របស់អង្គភាពសង្គមស៊ីវិល"



៣.កាលពីថ្ងៃចន្ទ ៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែតុលា គ.ស. ២០២៤ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោកស្រី ឆាន់ ចេត្តនា** អនុប្រធានការិយាល័យអនុលោមភាពទី៣ ព្រមទាំងមន្ត្រីបច្ចេកទេស បានចូលរួមកិច្ចប្រជុំលើសេចក្ដីសម្រេចស្ដីពី " ការបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើនិងសំណូមពរ របស់អង្គភាពសង្គមស៊ីវិល" នៅសាលប្រជុំខេត្តសៀមរាប នៃទីស្ដីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាប្រធានក្រុមការងារ។ កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអនុប្រធាន និងសមាជិកនៃក្រុមការងារព្រមទាំងមន្ត្រីពាក់ព័ន្ធផ្សេងទៀតផងដែរ។

## "វេទិកាគណនេយ្យសាធារណៈប្រចាំតំបន់របស់ ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២៤"



៤.កាលពីព្រឹកថ្ងៃពុធ ១៥រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែតុលា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ៃ ថារិន** អគ្គនាយក **និយ័តករគណនេយ្យនិងសវនកម្ម លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ នៃនាយកដ្ឋានបច្ចេកទេស បានចូលរួម "វេទិកាគណនេយ្យសាធារណៈប្រចាំតំបន់របស់ ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០២៤" ដែលបានប្រព្រឹត្ត ទៅកាលពីថ្ងៃទី២-៣ ខែតុលា គ.ស. ២០២៤ នៅសណ្ឋាគារ Fairmont Makati ទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន៕ វេទិកានេះត្រូវបានសហការ រៀបចំ ឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSASB) ក្នុងគោលបំណង អនុញ្ញាតឱ្យមន្ត្រីរដ្ឋាភិបាល នៃបណ្តាប្រទេសកំពុងអភិវឌ្ឍដែលជាសមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់មតិយោបល់ជាធាតុចូលបន្ថែម ទៅកាន់ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ និងលើកកម្ពស់សមត្ថភាពគណនេយ្យសាធារណៈរបស់ខ្លួនតាមរយៈការបង្កើននូវចំណេះដឹងពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ និងឧត្តមានុវត្តន៍ជាអន្តរជាតិ ដើម្បីបន្តធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគណនេយ្យនៃប្រទេសរបស់ខ្លួន៕ វេទិកាឆ្នាំ២០២៤ នេះក៏បានលើក ឡើងអំពីការរាយការណ៍ព័ត៌មានចីរភាពសម្រាប់ស្ថាប័នសាធារណៈដែលរំពឹងថានឹងចេញផ្សាយនូវសេចក្តីព្រាងស្តង់ដាការលាតត្រដាងពាក់ព័ន្ធនឹងអាកាសធាតុនាចុងឆ្នាំ២០២៤។

## កិច្ចប្រជុំវឌ្ឍនភាពការងារក្នុងការរៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៤



៥.កាលពីថ្ងៃចន្ទ ៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែតុលា គ.ស.២០២៤ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ៃ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកិច្ចប្រជុំក្រុមការងារបង្គោលដើម្បី៖ ១-ពិនិត្យវឌ្ឍនភាពការងារមួយចំនួនក្នុងការរៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ក្រោមប្រធានបទ"តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០"។ ២-កំណត់សកម្មភាពអាទិភាព និងរៀបចំក្រុមការងារលម្អិតដើម្បីរៀបចំវេទិកា។ កិច្ចប្រជុំនេះ មានការចូលរួមពី លោក លោកស្រី អគ្គនាយករង វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ACCA ប្រចាំប្រទេសកម្ពុជា ព្រមទាំងកិច្ចសហការគាំទ្រពីក្រុមហ៊ុន DFC ក្រុមហ៊ុន Banhji និងក្រុមការងាររបស់ **ន.គ.ស.**។

## វគ្គបណ្តុះបណ្តាលស្តីពី "ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង" ជូនដល់មន្ត្រីថ្មីរបស់ ន. គ. ស.




៦.កាលពីថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព. ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែតុលា គ.ស.២០២៤ **ឯកឧត្តម ម៉ៃ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោក ជា ចាន់ថា** អគ្គនាយករង និង**លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋាន

កិច្ចការទូទៅ បានចូលរួមបណ្តុះបណ្តាលស្តីពី "ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង" ជូនដល់មន្ត្រីថ្មីរបស់ **ន. គ. ស.** នៅអគារ ៣៤៥។ ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គនាយក** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅនិងបានលើកឡើងអំពីគោលបំណងនៃការរៀបចំវគ្គនេះគឺជាការកសាងសមត្ថភាពមន្ត្រីជំនាញទាំងផ្នែកទន់និងផ្នែករឹង ដែលជាសកម្មភាពមួយនៅក្នុងផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បកម្ម ១០ឆ្នាំ ក៏ដូចជាផ្នែកមួយក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម ១០ឆ្នាំ របស់ **ន. គ. ស.**។ ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ មានបាវចនា ៥ គឺ "កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព" របស់រាជរដ្ឋាភិបាល។ **ន.គ.ស.** នឹងមានវគ្គបណ្តុះបណ្តាលលើប្រធានបទបច្ចេកទេសសំខាន់ៗដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីបន្តទៀតដែលពាក់ព័ន្ធ និងការអនុវត្តការងារផ្ទាល់ក្រោមមុខងារភារកិច្ចរបស់**ន. គ. ស.** ផងដែរ។

## កិច្ចប្រជុំអនុគណៈកម្មាធិការទាំង៣ នៃកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.) លើកទី៤




៧.កាលពីថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែតុលា គ.ស.២០២៤ **ឯកឧត្តម ម៉ុ ថារិន** អគ្គនាយកនៃ**និយ័តករគណនេយ្យនិងសវនកម្ម** និងជាអនុប្រធានប្រចាំការរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា បានដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការទាំង៣នៃកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.) លើកទី៤ ដោយមានការអញ្ជើញចូលរួមពី **លោកស្រី នាន បូនី** ប្រធាន នៃអនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង **លោក ហុង ពិសិដ្ឋ** ប្រធាននៃអនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា **លោក សាយ សុខខេង** ទីប្រឹក្សាបច្ចេកទេស របស់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា និងលេខាធិការដ្ឋាន ដើម្បីពិនិត្យនិងពិភាក្សាទៅលើវឌ្ឍនភាពការងារសម្រាប់ឆមាសទី២ របស់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

## កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ



៨.កាលពីថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែតុលា គ.ស.២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល សម្រាប់សហគ្រាសធុនតូចនិងមធ្យមនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ិ ថារិន អគ្គនាយក** នៃ**និយ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាពនិងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ**និយ័តករគណនេយ្យនិងសវនកម្ម** ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ចំនួន១៣៧នាក់ ផងដែរ។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល ជូនសហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## កិច្ចប្រជុំពិនិត្យនិងពិភាក្សាអំពី "សេចក្តីព្រាងទម្រង់និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល"



៩.កាលពីថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែតុលា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ិ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាអំពី "សេចក្តីព្រាងទម្រង់និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល" ជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ នៅអគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កម្មវិធីបិទវគ្គបណ្តុះបណ្តាលស្តីពី "ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង" ជូនដល់មន្ត្រីថ្មីរបស់ ន.គ.ស.



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១០.កាលពីថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព. ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែតុលា គ.ស.២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** បានរៀបចំកម្មវិធីបិទវគ្គបណ្តុះបណ្តាលស្តីពី "ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង" ជូនដល់មន្ត្រីថ្មីរបស់ **ន. គ. ស.** នៅអគារ ៣៤៥ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ុ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម**។ **លោកស្រីអគ្គនាយករង** ក៏បានឡើងពីគោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺជាការកសាងសមត្ថភាព ទាំងផ្នែករឹងនិងទន់ជូនដល់មន្ត្រីនៃ **ន. គ. ស.** ក៏ដូចជាយោងតាមផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្ម១០ឆ្នាំ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម។ មុននឹងបញ្ចប់ **លោកស្រីអគ្គនាយករង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូបង្គោល ក្រុមការងារ និងមន្ត្រីនៃ **ន. គ. ស.** ដែលបានចូលរួមនិងសម្របសម្រួលវគ្គបណ្តុះបណ្តាលនេះ។ **លោកស្រីអគ្គនាយករង** សង្ឃឹមថាវគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់នូវការយល់ដឹងបន្ថែមអំពីការគ្រប់គ្រង ក៏ដូចជារបៀបក្នុងការអនុវត្តការងារឱ្យកាន់តែមានភាពប្រសើរឡើងថែមមួយកម្រិតទៀត។

## កិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ




១១.កាលពីថ្ងៃសុក្រ ៩កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែតុលា គ.ស.២០២៤ នៅបន្ទប់ប្រជុំធំនៃ **និយ័តករគណនេយ្យនិងសវនកម្ម ឯកឧត្តម ខី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារបច្ចេកទេសស្តង់ដាគណនេយ្យ សម្រាប់វិស័យសាធារណៈ អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស ព្រមទាំងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានដឹកនាំកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖១).សេចក្តីព្រាងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ១ ស្តីពី "ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ" លេខ២ ស្តីពី "របាយការណ៍លំហូរសាច់ប្រាក់" និង លេខ ១២ ស្តីពី "សន្និធិ",២).សេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១, លេខ ២, លេខ ១២ និង៣).ទម្រង់និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល។

## វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្ម



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១២.កាលពីថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែតុលា គ.ស.២០២៤ **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** បានដឹកនាំ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្ម ។ **ន.គ.ស.** បានសហការជាមួយ ក្រុមហ៊ុន អឺនស្ទ៍អែនយ៉ាំង (ខេមបូឌា) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្មជូនដល់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃការិយាល័យត្រួតពិនិត្យទី១និង២នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងផ្តល់ឱកាសជូនដល់ ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **ន.គ.ស.** ឱ្យទទួលបានការយល់ដឹងបន្ថែមស្តីពី វិធីសាស្ត្រ នីតិវិធី និងការអនុវត្តការងារសវនកម្ម មានរយៈពេល៣ថ្ងៃ។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើ "ការផ្តល់ព័ត៌មានស្តីពីតម្រូវការទីប្រឹក្សាបច្ចេកទេស សម្រាប់គាំទ្រការអនុវត្តសកម្មភាពកែទម្រង់គន្លឹះ ក្រោមក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤"




១៣.កាលពីថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែតុលា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស អមដោយ **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ និងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "ការផ្តល់ព័ត៌មានស្តីពីតម្រូវការទីប្រឹក្សាបច្ចេកទេស សម្រាប់គាំទ្រការអនុវត្តសកម្មភាពកែទម្រង់គន្លឹះក្រោមក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤" ជាមួយ **លោក សេបាស្ទៀន ដ្យូប៊ុស** ប្រធានក្រុមនៃកម្មវិធី EU4PFMCambodia នៅបន្ទប់ប្រជុំធំនៃនិយ័តករគណនេយ្យនិងសវនកម្ម អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ "ផលិតភាពបច្ចេកទេសនិងអនុសាសន៍ដើម្បីធានាអនុលោមភាពតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិលេខ៤ ស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយបណ្ណបរទេស



១៤.កាលពីថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែតុលា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "ទិដ្ឋភាពបច្ចេកទេសនិងអនុសាសន៍ ដើម្បីធានាអនុលោមភាពតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិលេខ៤ ស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយបណ្ណបរទេស ជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ នៅបន្ទប់ប្រជុំធំនៃនិយ័តករគណនេយ្យនិងសវនកម្ម អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## វេទិកាជាតិគណនេយ្យ២០២៤ ក្រោមប្រធានបទ "តួនាទីនៃគណនេយ្យ និងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០"



១៥.កាលពីថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែតុលា គ.ស.២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវេទិកាជាតិគណនេយ្យ២០២៤ ក្រោមប្រធានបទ "តួនាទីនៃគណនេយ្យ និងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០"។ វេទិកាជាតិគណនេយ្យ២០២៤ នេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ព្រមទាំង ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធនានា និងមានការចូលរួមពីសំណាក់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ប្រមាណ១,៣៥០នាក់។



ក្នុងនោះផងដែរនាថ្ងៃសុក្រ ១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែតុលា គ.ស.២០២៤ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** បានថ្លែងសុន្ទរកថា បើកវេទិកាជាតិគណនេយ្យថ្ងៃទី២ ដែលផ្តោតសំខាន់ទៅលើការអភិវឌ្ឍមូលធនមនុស្សជាគណនេយ្យករជំនាញ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម តំណាងសហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសិស្សានុសិស្ស ចំនួនប្រមាណ ១,៣០០នាក់ ផងដែរ។

## ពិភាក្សាលើកិច្ចការអាទិភាពក្នុងការគ្រប់គ្រងរតនាគារនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




១៦.កាលពីថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែតុលា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និង **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ បានទទួលជួប **លោកស្រី Sha Wen** ទីប្រឹក្សារតនាគារប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីពិភាក្សាលើកិច្ចការអាទិភាពក្នុងការគ្រប់គ្រងរតនាគារនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅបន្ទប់ប្រជុំធំនៃ**និយ័តករគណនេយ្យនិងសវនកម្ម** អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំពិភាក្សា និងវគ្គបណ្តុះបណ្តាលក្រោមការបង្ហាត់បង្រៀនរបស់លោក Stephen Van Kempen ប្រធានដឹកនាំត្រួតពិនិត្យ ( មកពី PUM Netherland ) និងអ្នកត្រួតពិនិត្យឯករាជ្យក្នុងស្រុក




១៧.កាលពីថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែតុលា គ.ស.២០២៤ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃការិយាល័យត្រួតពិនិត្យទី១ និងការិយាល័យត្រួតពិនិត្យទី២ នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំពិភាក្សានិងវគ្គបណ្តុះបណ្តាលក្រោមការបង្ហាត់បង្រៀនរបស់ លោក Stephen Van Kempen ប្រធានដឹកនាំត្រួតពិនិត្យ (មកពី PUM Netherland) និងអ្នកត្រួតពិនិត្យឯករាជ្យក្នុងស្រុកដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.គ.ស.** និងអ្នកអង្កេតការណ៍ពីវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា នៅបន្ទប់ប្រជុំធំ ( **ន.គ.ស.** ) អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រជុំពិភាក្សានិង

វគ្គបណ្តុះបណ្តាលដែលប្រព្រឹត្តទៅក្នុងរយៈពេល៣ថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងពិភាក្សាអំពីនីតិវិធីនៃការចុះត្រួតពិនិត្យគុណភាពសវនកម្មក៏ដូចជាពិភាក្សាលើរបៀបវារៈសំខាន់ៗក្នុងកិច្ចដំណើរការនៃការចុះត្រួតពិនិត្យគុណភាពសវនកម្ម គ.ស.២០២៤នេះ។

## កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៥ (25th ACPACC) នៅទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី




១៨.កាលពីថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែតុលា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មាធិការសម្រសបម្រួលគណនេយ្យករជំនាញអាស៊ាន បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៥ (25th ACPACC) និងតំណាងគណៈកម្មាធិការសម្រសបម្រួលគណនេយ្យករជំនាញអាស៊ាន រាយការណ៍អំពីលទ្ធផលកិច្ចប្រជុំជូនកិច្ចប្រជុំក្រុមការងារធុរកិច្ចតាមវិស័យ (BSSWG) នៅទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី ដែលមានការចូលរួមតំណាងប្រទេសកម្ពុជារួមមាន **លោក ណុប សម្បត្តិ លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋាន, **លោក ស៊ុន ស៊ឹម** ប្រធានការិយាល័យ, **លោកស្រី វណ្ណា ពៅដានូ** អនុប្រធានការិយាល័យ, **លោក យេង សុខជី លោកស្រី ទឹម ដានិត** មន្ត្រីនៃ**និយ័តករគណនេយ្យនិងសវនកម្ម** និងតំណាងប្រទេសជាសមាជិកអាស៊ាន។

## កម្មវិធីគម្រប់ខួប ២០ឆ្នាំ នៃការបង្កើតវេទិកាទីផ្សារមូលបត្រអាស៊ាន (ACMF) និងសន្និសីទអន្តរជាតិឆ្នាំ២០២៤




១៩.កាលពីថ្ងៃអង្គារ ៥រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែតុលា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម លោក ពេជ សុភាចារ** និង **លោក អ៊ុន បូផា អេលីត** មន្ត្រីជំនាញនៃ**និយ័តករគណនេយ្យនិងសវនកម្ម** បានចូលរួមកម្មវិធីគម្រប់ខួប២០ឆ្នាំ នៃការបង្កើតវេទិកាទីផ្សារមូលបត្រអាស៊ាន (ACMF) និងសន្និសីទអន្តរជាតិគ.ស.២០២៤ ក្រោមប្រធានបទ "បង្កើនការអភិវឌ្ឍក្នុងតំបន់តាមរយៈការលើកកម្ពស់ទំនាក់ទំនង,ចីរភាពនិងភាពធន់

តាមបណ្តាទីផ្សារមូលបត្រអាស៊ាន" និងវគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពី"ស្តង់ដា IFRS ការលាតត្រដាងព័ត៌មានចីរភាព"។ សន្និសីទ និងវគ្គបណ្តុះបណ្តាលនេះមានរយៈពេលពីរថ្ងៃគឺថ្ងៃទី២២-២៣ ខែតុលា គ.ស.២០២៤ នៅទីក្រុងវៀងច័ន្ទន៍ ប្រទេសឡាវ ក្រោមការរៀបចំរបស់គណៈកម្មការមូលបត្រនៃប្រទេសឡាវ ដែលមានការចូលរួមពីស្ថាប័នអន្តរជាតិ និយ័តករមូលបត្រកម្ពុជា និងនិយ័តករគណនេយ្យនិងសវនកម្ម ដែលជាសមាជិក ACMF និងភាគីពាក់ព័ន្ធក្នុងវិស័យមូលបត្រអាស៊ាន។ សន្និសីទ និងវគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើងក្នុងគោលបំណង៖ ១)ការអនុម័តគោលការណ៍ណែនាំស្តីពីហិរញ្ញវត្ថុអន្តរកាលអាស៊ាន (ASEAN Transition Finance Guidance - ATFG) និង ២)ការចែករំលែកអំពីវឌ្ឍនភាពនៃការអនុវត្តការរាយការណ៍ព័ត៌មានចីរភាពរបស់ប្រទេសមួយចំនួននៅក្នុងអាស៊ាន។

## កិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជាមួយសមាគមអាជីវកម្ម



២០.កាលពីថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែតុលា គ.ស. ២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជាមួយសមាគមអាជីវកម្ម នៅអាគារ ៣៤៥។ កិច្ចប្រជុំពិភាក្សាលើការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី ព្រមទាំងសមាជិក សមាជិកា នៃសមាគមអាជីវកម្មរួមមាន៖ សមាគមស្បែកជើងកម្ពុជា,សមាគមផលិតផលធ្វើដំណើរនិងស្បែកនៅកម្ពុជា,សមាគមវាយនភណ្ឌសម្លៀកបំពាក់ស្បែកជើងនិងផលិតផល,សមាគមអភិវឌ្ឍន៍លំនៅឋាន និងមាគមអ្នកសាងសង់នៅកម្ពុជា ដែលមានអ្នកចំនួន១២៥នាក់។

## កិច្ចប្រជុំលើកទី១ "ក្រុមការងារជំរុញការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៅក្នុងវិស័យធានារ៉ាប់រងកម្ពុជា"



២១.កាលពីថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែតុលា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង នៃ**និយ័តករគណនេយ្យនិងសវនកម្ម**និងជាអនុប្រធានក្រុមការងារ និង **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេសនិងជាសមាជិកនិងមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេសបានចូលរួមកិច្ចប្រជុំលើកទី១ "ក្រុមការងារជំរុញការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៅក្នុងវិស័យធានារ៉ាប់រងកម្ពុជា" ដែលដឹកនាំដោយ **ឯកឧត្តម ម៉ី ច័ន្ទតិរ្ទ** អគ្គនាយក និយ័តករធានារ៉ាប់រងកម្ពុជានិងជា

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

ប្រធានក្រុមការងារ ដើម្បីពិភាក្សានិងពង្រឹងការសិក្សាស្រាវជ្រាវលើការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ១៧ និងលេខ៩ ក្នុងវិស័យធានារ៉ាប់រង នៅបន្ទប់ប្រជុំជាន់ទី៦ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងគម្រោងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ប្រចាំប្រទេសកម្ពុជា និងធនាគារជាតិនៃកម្ពុជា



២២.កាលពីថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែតុលា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ**លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានបច្ចេកទេស និង **លោក វុធ ឪកាណាល់** មន្ត្រីបច្ចេកទេស និងមន្ត្រីនៃនិយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ  បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងគម្រោងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ប្រចាំប្រទេសកម្ពុជា និងធនាគារជាតិនៃកម្ពុជា។ កិច្ចប្រជុំនេះ ដឹកនាំដោយ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយផ្តោតសំខាន់ទៅលើការអនុវត្តគម្រោងការលើកកម្ពស់សមត្ថភាពនៃការវិនិយោគសេដ្ឋកិច្ច ការស្រាវជ្រាវ និងប្រតិបត្តិការសម្រាប់គោលនយោបាយរូបិយវត្ថុនៅធនាគារជាតិនៃកម្ពុជា។

## ពិធីប្រកាសផ្សព្វផ្សាយនិងដាក់ឱ្យដំណើរការ "ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្ណសារ"



២៣.កាលពីថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែតុលា គ.ស.២០២៤ នៅខេត្តសៀមរាបដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **លោក ឈុត វិច័យ** អនុប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក អមដោយ **លោក ផាត ច័ន្ទជីវ៉ា** មន្ត្រីការិយាល័យរដ្ឋបាលនិងបុគ្គលិក បានចូលរួមពិធីប្រកាសផ្សព្វផ្សាយនិងដាក់ឱ្យដំណើរការ "ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្ណសារ" ក្រោមអធិបតីភាព **ឯកឧត្តម ឯក ចន្ថា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី

តំណាងអង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ព្រមទាំងក្រុមការងារនៃអគ្គលេខាធិការដ្ឋានក្រសួង។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា



២៤.កាលពីថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែតុលា គ.ស.២០២៤ នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួម "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំនិងសមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅទីស្តីការ (**អ.ស.ហ.**)។

## គោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម ជា ចាន់តូ តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ




២៥.កាលពីថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែតុលា គ.ស.២០២៤ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋាន និង **លោក យេង សុធី** មន្ត្រីនៃ **ន.គ.ស**. បានអញ្ជើញចូលរួមជាមួយគណៈប្រតិភូរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលដឹកនាំដោយ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ដែលបានទទួលមរណៈភាពកាលពីថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែតុលា គ.ស. ២០២៤ វេលាម៉ោង ១០:៣០នាទីព្រឹក ក្នុងជន្មាយុ ៧៣ឆ្នាំ ដោយរោគាពាធ។

## កិច្ចប្រជុំស្តីពី "ការប៉ះពាល់ដល់ការត្រួតពិនិត្យសវនកម្មសកល
(Impacting Auditing Oversight Globally)"



២៦.កាលពីថ្ងៃអង្គារ ១២រោច ខែតុលា ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែតុលា គ.ស.២០២៤ **ឯកឧត្តម ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដឹកនាំថ្នាក់ដឹកនាំ និងមន្ត្រីនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ចូលរួមកិច្ចប្រជុំស្តីពី "ការប៉ះពាល់ដល់ការត្រួតពិនិត្យសវនកម្មសកល (Impacting Auditing Oversight Globally)" ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២៩-៣០ ខែតុលា គ.ស.២០២៤ នៅរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក។

## វេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤"
## ក្រោមប្រធានបទ "បរធនបាលកិច្ចៈ លើសពីថ្នាលបង្កើតទំនុកចិត្ត"



២៧.កាលពីថ្ងៃពុធ ១៣រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែតុលា គ.ស.២០២៤ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃ**និយ័តករគណនេយ្យនិងសវនកម្ម** បានអញ្ជើញចូលរួមវេទិកា "បរធនបាលកិច្ច គ.ស.២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ចៈ លើសពីថ្នាលបង្កើតទំនុកចិត្ត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារសុខាភ្នំពេញ។

## កម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ




២៨.កាលពីថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែតុលា គ.ស. ២០២៤ **និយ័តករគណនេយ្យ និងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារចំនួន២វគ្គ នៅអគារ៣៤៥។ កម្មវិធីប្រគល់វិញ្ញាបនបត្រនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ឈាង ឆេងហាន** អនុប្រធាននាយកដ្ឋានទទួលនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោម ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ និងក្រុមហ៊ុនឌីអេស្វស៊ី ផងដែរ ។

## កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ"




២៩.កាលពីថ្ងៃព្រហស្បតិ៍ ១៤ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែតុលា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម, **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋាន

បច្ចេកទេស អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជីកាគណនេយ្យនៃសន្និធិ" និង"សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស" ដែលដឹកនាំដោយ **លោក ជា សុជាតិ** ប្រធាននាយកដ្ឋានគោលការណ៍គណនេយ្យ និងវិភាគការអនុវត្តថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការចូលរួមពីតំណាងនិយ័តករគណនេយ្យនិងសវនកម្ម, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ។

រៀបចំដោយ ÷ **លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ៖ **កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម